# ការបណ្ដុះសាកគ្រាប់ពូជស្រូវ

## ១-គោលបំណង

- ដើម្បីអោយដឹងភាគរយ នៃការដុះពន្លក របស់ពូជដែលត្រូវសាប
- ដើម្បីកំនត់បរិមាណពូជអោយត្រូវចំនួនដែលត្រូវប្រើ

## ២-ការជ្រើសរើសពូជ

- ពូជមានប្រភពច្បាស់លាស់
- ពូជទុំល្អ
- ពូជគ្មានជំងឺ និងសត្វល្អិតបំផ្លាញ
- ពូជមានដំណុះពី ៨០ ភាគរយឡើង

## ៣-សំភារៈ

គ្រាប់ពូជ ក្រណាត់រុំ (ទំហំ ២តឹក៤ជ្រុង) របាឬស្សីទំហំប៉ុនម្រាមដៃប្រវែងប្រហែល៤តឹក កៅស៊ូរតង់ ប៊ិច និង ក្រដាស់ ។

## ៤-របៀបអនុវត្ត

- យកគ្រាប់ពូជចំនួន ១០០គ្រាប់ (ចាប់ដោយចៃដន្យ)
- តំរៀបគ្រាប់ពូជលើក្រណាត់សើម (ជក់ទឹក) ចំនួន ១០ជួរ ១ ជួរ =១០គ្រាប់
- មូរវាជាមួយរបាឬស្សី
- សរសេរឈ្មោះពូជ ថ្ងៃខែបណ្ដុះសាក លើក្រដាស់ រួចចងវាទៅនឹងចុងរបាឬស្សី
- ក្នុង ១ថ្ងៃត្រូវជ្រលក់ទឹកចំនួន ៣ដង ក្នុង ១ដង រយៈពេល ២-៣ នាទី ធ្វើរបៀបនេះ រយៈពេល ៣ថ្ងៃ
- លារមូរក្រណាត់ រួចរាប់ចំនួនគ្រាប់ស្រូវដែលដុះពន្លក ។



**៥-ចំនុចត្រូវចងចាំ**

-ត្រូវរក្សាទុករមូរគ្រាប់ស្រូវ នៅកន្លែងមានសុវត្ថិភាព (ឆ្ងាយពីដៃក្មេង និងសត្វបំផ្លាញ )

-គ្រាប់ពូជអាចប្រើបានលុះត្រាមានដំណុះចាប់ពី ៨០គ្រាប់ ឬ ៨០ភាគរយឡើង

-បើយើងប្រើពូជដុះតិចជាង ៨០ភាគរយ លុះត្រាណាយើងបន្ថែមគ្រាប់ពូជ អោយទៅតាមភាគរយ របស់វា

-ការបណ្ដុះសាកគឺធ្វើអោយអ្នករវល់បន្តិចមែនតែក៏ជួយអោយអ្នកចំណេញពូជ ពេលវេលា ប្រាក់ និងមានទំនុកចិត្តទៅលើពូជរបស់យើងដែរ ។



# ការសាបសំណាបនៅលើថ្នាលទឹក

**១-គោលបំណង**

ដើម្បីទទួលបានសំណាបថ្លោសល្អ គ្មានជំងឺ និងសត្វល្អិតបំផ្លាញ ដើម្បីស្ទូង

**២-ការជ្រើសរើសទីកន្លែង** ការជ្រើសរើសទីកន្លែងមានដូចខាងក្រោម ៖

- ជិតប្រភពទឹក
- ដីមានជីជាតិល្អ
- ស្ថិតនៅក្បែរផ្ទះ
- នៅក្បែរស្រែសំរាប់ស្ទូង
- ឆ្ងាយពីម្លប់ឈើ និងមាន ផ្ទៃដី ពី ៨០០-១០០០ ម$^{២}$ សំរាប់ស្ទូងផ្ទៃដី ១ហ.ត (ប្រើពូជ ៤០គ.ក្រ )។

**២-ការរៀបចំថ្នាល**

- បញ្ចូលទឹកក្នុងថ្នាល ១-២ថ្ងៃ មុននឹងភ្ជួរ
- ភ្ជួរ ២ដង
- រាស់អោយបានច្រើនសារលុះត្រាតែដីម៉ត់ល្អ និងសំអាតស្មៅអោយបានស្អាតល្អ
- កៀរដីថ្នាលអោយបានស្មើល្អ
- ឆូតជាគន្លងចែកដីថ្នាលតូចៗ ទទឹង ១,៥ទៅ ២ម៉ែត្រដើម្បីងាយស្រួលបញ្ចេញបញ្ចូលទឹក និងថែទាំផ្សេងៗ
- លើករងកូនថ្នាលសំណាបកំពស់ ៤-៥ស.ម រួចកៀរដីលើថ្នាលនោះអោយរាបស្មើល្អ
- ចង្អូរប្រវែង ២០-២៥ស.ម



**៣-ការត្រាំគ្រាប់ពូជ**



ត្រាំ ២៤ម៉ោង

- លាងគ្រាប់ពូជអោយបានស្អាត ជាមួយទឹកស្អាត
- ច្រកចូលក្នុងបាវ ឬក្នុងខាប់ក៏បានហើយចងមាត់កុំអោយ តឹងពេកក ងាយស្រួលស្រូវរីក
- ត្រាំរយៈពេល ២៤ម៉ោង ។

**៤-ការផ្អាប់**

- លាងគ្រាប់ពូជដែលបានត្រាំអោយបានច្រើនដង ហើយច្រកបាវវិញ
- យកបាវស្រូវទៅដាក់ក្នុងម្លប់ និងយកចំបើងគ្របពីលើ ដើម្បីអោយឡើងកំដៅខ្ពស់
- ១២ម៉ោងក្រោយមកត្រូវត្រឡប់បាវ ហើយស្រោច ទឹកស្ទើមតិច១




- ផ្អាប់រយៈពេល ២៤ ម៉ោង ទៅ ៤៨ ម៉ោង
- គ្រាប់ពូជចេញឬស ប្រវែង ២-៣ ស.ម ទើបយកទៅសាប

**៥-ការសាប**

- ត្រូវសាបអោយស្មើដែលកុំស្តើង កុំក្រាស
- សាបលើថ្នាលមានទឹកផុក១
- ពូជ ១ទូកដៃ ឬ ១ខាំ ត្រូវសាបលើផ្ទៃដី ១,៥-២ ម$^{២}$
- ត្រូវសាបនៅពេលល្ងាចត្រជាក់

**៦-ការថែទាំសំណាប**

**ក-ការបញ្ចូលទឹក**

- ក្រោយសាបបាន ៣-៤ថ្ងៃ បញ្ចូលទឹកជំរៅ ២-៣ស.ម រយៈពេល ១០ថ្ងៃ
- បន្ទាប់បកបង្កើនជំរៅទឹក ដល់ ៥ ស.ម រហូតដល់មុនដក ១ថ្ងៃ
- មុនដក ១ថ្ងៃ ត្រូវបង្កើនជំរៅទឹករហូតដល់ ១០ស.ម ដើម្បីដកកុំអោយដាច់ឬសសំណាប ។

**ខ-ការបាចជីបំប៉នសំណាប**

- នៅពេលសំណាបអាយុបាន ១០ថ្ងៃ បើឃើញសំណាបដើមតូចខ្សោយស្លឹកពណ៌លឿងខ្ចីត្រូវបាចជីអ៊ុយរ៉េ (ជីក្រាម ឬពងខ្យង )ចំនួន 0,៥គ.ក្រ /១អារ (១០០ម$^{២}$)
- បាចជីនៅកំពស់ទឹក ២-៣ស.ម (១-១,៥ ថ្នាំងដៃ)

**៧-ចំណុចត្រូវចងចាំ**

- ជៀសវាងការសាបញឹក ឬក្រាសពេកបណ្តាលអោយដើមសំណាបតូចឆ្មារ ហើយខ្សោយ
- ត្រូវពន្យាពេលសាបរហូតដល់ភ្លៀងរាំង
- មិនត្រូវបាចជីបំប៉នទេនៅពេលសំណាបថ្លោសល្អ និងមានស្លឹកពណ៌បៃតងចាស់

# បច្ចេកទេសដាំដុះស្រូវ

## ១-ការរៀបចំដី

- ភ្ជួរចំនួន ២ដង
- រាស់សំអាតស្មៅអោយបានស្អាតល្អ
- កៀរដីអោយបានស្មើល្អ

## ២-ការរៀបចំសំណាបសំរាប់ស្ទូង

- សំណាបអាយុ ១៨-២៥ថ្ងៃ (ចំពោះស្រូវស្រាល )
- សំណាបអាយុ ៣០-៣៥ថ្ងៃ (ចំពោះស្រូវកណ្តាល )
- សំណាបអាយុ ៤០-៤៥ថ្ងៃ (ចំពោះស្រូវធ្ងន់ )
- ពេលដកសំណាបភ្លាមត្រូវស្ទូងភ្លាម
- ត្រូវដាក់សំណាបក្នុងភ្លប់ ឬត្រាំឬសក្នុងទឹក បើពុំទាន់យកទៅស្ទូង ដើម្បីកុំអោយអន់សំណាប
- ត្រូវកាត់ចុងចេញបន្តិច បើសិនសំណាបនោះមានស្លឹកច្រើន

## ៣-បច្ចេកទេសនៃការស្ទូង

### ក-ចំនួនដើមស្ទូង

- ស្ទូង ១-៣ ដើម ក្នុង ១គុម្ព ចំពោះស្រូវទំនើប
- ស្ទូង ៣-៤ ដើម ក្នុង ១គុម្ព ចំពោះស្រូវបុរាណ ព្រោះលទ្ធភាពបែកគុម្ពមានចំនួនតិចជាងស្រូវទំនើប

### ខ-ជំរៅស្ទូង

- ស្ទូងជំរៅ ២-៣ស.ម (កន្លះថ្នាំងដៃ ទៅមួយថ្នាំងដៃ )
- បើស្ទូងជ្រៅពេកធ្វើអោយការបែកគុម្ពតិច និងលូតលាស់យឺត

### គ-ចន្លោះស្ទូង

- ចន្លោះស្ទូង អាស្រ័យទៅលើពូជស្រូវ ជីជាតិដី រដូវកាលដាំដុះ
    - + ពូជស្រូវទំនើប ១៥ ស.មx ២០ ស.ម , ២០ ស.ម x ២០ ស.ម
    - + ពូជស្រូវក្នុងស្រុក ២៥ ស.ម x ២៥ ស.ម , ៣០ ស.មx ៣០ ស.ម
    - + អាចមានចន្លោះគុម្ពធំ ឬតូចជាងនេះអាស្រ័យទៅលើដីមានជីជាតិ ឬគ្មានជីជាតិល្អ

### ឃ-ការថែទាំ

- ការគ្រប់គ្រងទឹក
    - + ធ្វើភ្លឺអោយបានល្អ
    - + ក្រោយពីស្ទូងបាន ១-២ថ្ងៃ ពេលដែលសន្ទូងចាប់ឬសហើយត្រូវបញ្ចូលទឹកកំពស់២-៣ស.ម
    - + នៅវគ្គបង្កបង្កើនផល ត្រូវបង្កើនកំពស់ទឹក ដល់ ៥-១០ស.ម
    - + មុនច្រូត ១-២សប្តាហ៍ត្រូវបង្ហូរទឹកចេញ ដើម្បីបង្កើនល្បឿន នៃការទុំអោយបានឆាប់រហ័ស ។

**ខ-សំអាតស្មៅចង្រៃ**

- ត្រូវសំអាតស្មៅក្នុងស្រែ និងនៅតាមភ្លឺអោយបានស្អាតល្អ

- ស្មៅវាដណ្តើមយកជីជាតិ ,ពន្លឺ និងជាជំរកសត្វល្អិតចង្រៃ

**ច-ការបាចជីបំប៉ន** ចំនួន ២ លើក

**- លើកទី ១** មុនពេលបែកគុម្ព ៧ថ្ងៃ

**- លើកទី ២** មុនពេលកំនកំនើតកួរ ៧ថ្ងៃ

**- កំរិតជីប្រើប្រាស់** អាស្រ័យទៅតាមប្រភេទនៃក្រុមដី

**ឆ-ការបាចជីទ្រាប់បាត**

- ប្រើមុនស្ទូង

- ប្រភេទជី

  + ជីធម្មជាតិ

  + ជីគីមី អាស្រ័យទៅតាមប្រភេទនៃក្រុមដី

# ការប្រើប្រាស់ជីទ្រាប់បាតលើដំណាំស្រូវ
# (ក្រុមដីកំពង់សៀម)

## ១-ប្រភេទជីដែលត្រូវប្រើ

**ក-ជីធម្មជាតិ**

- ជីកំប៉ុស្តដែលផ្សំដោយកាកសំណល់ ស្លឹកឈើ លាមកសត្វ ដែលប្រមូលដាក់ក្នុងរណ្តៅក្នុងរយះពេលមួយដើម្បីអោយវារលួយពុកផុយល្អ ។
- ជីលាមកសត្វដែលពុកផុយល្អ ឬគ្មានក្លិនស្អុយ (ជីអាចម៍គោ ក្របី ជ្រូកមាន់ ទា )
- ជីស្រស់ (ដើម ស្លឹកកន្ទ្រានខែត្រ ដើម ស្លឹកសណ្តែកគ្រប់ប្រភេទ កំផ្លោក ស្នោរ ចកស្រស់ )

**ខ-ជីគីមី**

-ជី អ៊ុយរ៉េ (Urea) មានពណ៌ស (ដែលកសិករហៅថាជីឆាំងលាវ ឬជីពងខ្យង )

## ២-ពេលវេលាប្រើជីទ្រាប់បាត

**ក-ជីធម្មជាតិ** ÷ បាចនៅបន្ទាប់ពីភ្ជួរលើកទី ១ រួចរាល់លប់ទៅក្នុងដី ។

**ខ-ជីគីមី** ÷ បាចបន្ទាប់ពីភ្ជួរលើកទី ២ រួចរាស់លប់ទៅក្នុងដី ។

## ៣-បរិមាណជីដែលត្រូវប្រើ

**ក-ជីធម្មជាតិ** ចំនួន ១០-១៥ ដឹក ក្នុង ១ហ.ត

**ខ-ជីគីមី**

+ ជី អ៊ុយរ៉េ ចំនួន ៥៥ គ.ក្រ

+ បាចលើផ្ទៃដី ១ហ.ត

## ៤-ចំណុចត្រូវចងចាំ

- មិនត្រូវបោះបង់ចោលការប្រើប្រាស់ ***ជីធម្មជាតិ*** សំរាប់ទ្រាប់បាត
- មិនត្រូវបាចជី ***អ៊ុយរ៉េ*** លើដីស្រែដែលគ្មានទឹកសោះ
- មិនត្រូវប្រើជី ***អ៊ុយរ៉េ*** សំរាប់បំប៉នសន្ទូងទេ
- មិនត្រូវប្រើប្រាស់ជីគីមី ***អោយលើស*** ឬ ***ក៏ខ្វះ*** ពីសេចក្តីត្រូវការរបស់ដំណាំ ។

# ការប្រើប្រាស់ជីទ្រាប់បាតលើដំណាំស្រូវ
# (ក្រុមដីប្រទះឡាង)

**១-ប្រភេទជីដែលត្រូវប្រើ**

**ក-ជីធម្មជាតិ**

- ជីកំប៉ុស្ត ដែលផ្សំដោយកាកសំណល់ ស្លឹកឈើ លាមកសត្វ ដែលប្រមូលដាក់ក្នុងរណ្តៅក្នុងរយៈពេលមួយ ដើម្បីអោយវារលួយពុកផុយល្អ ។

- ជីលាមកសត្វ ដែលពុកផុយល្អ ឬគ្មានក្លិនស្អុយ (ជីអាចម៍គោ ក្របី ជ្រូក មាន់ ទា )

- ជីស្រស់ (ដើម ស្លឹកកន្ទ្រានខែត្រ ដើម ស្លឹកសណ្តែកគ្រប់ប្រភេទ កំផ្លោក ស្មោរ ចកស្រស់ )

**ខ-ជីគីមី**

- ជីដេ អា ប៉េ (DAP) មានពណ៌ប្រផេះ ឬខ្មៅ (ដែលកសិករហៅថាជីខ្មៅ )

- ជីប៉ូតាស្យូមក្លរួ (Kcl ) មានពណ៌ក្រហម (ដែលកសិករហៅថា ជីអំបិលម្ទេស )

**២-ពេលវេលាប្រើជីទ្រាប់បាត**

**ក-ជីធម្មជាតិ** ÷ បាចនៅបន្ទាប់ពីភ្ជួរលើកទី ១ រួចរាល់លប់ទៅក្នុងដី ។

**ខ-ជីគីមី** ÷ បាចបន្ទាប់ពីភ្ជួរលើកទី ២ រួចរាស់លប់ទៅក្នុងដី ។

**៣-បរិមាណជីដែលត្រូវប្រើ**

**ក-ជីធម្មជាតិ** ចំនួន ១០-១៥ដឹក ក្នុង១ហ.ត

**ខ-ជីគីមី**

+ ជី ដេ អា ប៉េ ចំនួន ៥០គ.ក្រ

+ ជី ប៉ូតាស្យូមក្លរួ ចំនួន ៥០គ.ក្រ

+ ត្រូវលាយជី ដេ អា ប៉េ និងជី ប៉ូតាស្យូមក្លរួ អោយបានស្មើសាច់ជាមុន មុនបាចទ្រាប់បាត

+ បាចលើផ្ទៃដី ១ហ.ត

**៤-ចំណុចត្រូវចងចាំ**

- មិនត្រូវបោះបង់ចោលការប្រើប្រាស់ ***ជីធម្មជាតិ*** សំរាប់ទ្រាប់បាត

- មិនត្រូវបាចជីគីមី ***ដេ អា ប៉េ*** និង ***ប៉ូតាស្យូមក្លរួ*** លើដីស្រែដែលគ្មានទឹកសោះ

- មិនត្រូវប្រើជីគីមី ***ដេ អា ប៉េ*** និង ***ប៉ូតាស្យូមក្លរួ*** សំរាប់បំប៉នសន្ទូងទេ

- មិនត្រូវប្រើប្រាស់ជីគីមី ***អោយលើស*** ឬ ***ក៏ខ្វះ*** ពីសេចក្តីត្រូវការរបស់ដំណាំ ។

# ការប្រើប្រាស់ជីទ្រាប់បាតលើដំណាំស្រូវ
# (ក្រុមដីក្រគរ ឬ កៀនស្វាយ)

**១-ប្រភេទជីដែលត្រូវប្រើ**

**ក-ជីធម្មជាតិ**

- ជីកំប៉ុស្ត ដែលផ្សំដោយ កាកសំណល់ ស្លឹកឈើ លាមកសត្វ ដែលប្រមូលដាក់ក្នុងរណ្តៅក្នុងរយៈពេល មួយ ដើម្បីអោយវារលួយពុកផុយល្អ ។

- ជីលាមកសត្វ ដែលពុកផុយល្អ ឬគ្មានក្លិនស្អុយ (ជីអាចម៍គោ ក្របី ជ្រូក មាន់ ទា )

- ជីស្រស់ (ដើម ស្លឹកកន្ទ្រានខែត្រ ដើម ស្លឹកសណ្តែកគ្រប់ប្រភេទ កំផ្លោក ស្មោរ ចកស្រស់ )

**ខ-ជីគីមី**

-ជីដេ អា ប៉េ (DAP) មានពណ៌ប្រផេះ ឬខ្មៅ (ដែលកសិករហៅថាជីខ្មៅ )

**២-ពេលវេលាប្រើជីទ្រាប់បាត**

**ក-ជីធម្មជាតិ** បាចនៅបន្ទាប់ពីភ្ជួរលើកទី ១ រួចរាស់លប់ទៅក្នុងដី ។

**ខ-ជីគីមី** បាចបន្ទាប់ពីភ្ជួរលើកទី ២ រួចរាស់លប់ទៅក្នុងដី ។

**៣-បរិមាណជីដែលត្រូវប្រើ**

**ក-ជីធម្មជាតិ** ចំនួន ១០-១៥ដឹក ក្នុង ១ហ.ត

**ខ-ជីគីមី**

+ ជី ដេ អា ប៉េ ចំនួន ៥0គ.ក្រ

+ បាចលើផ្ទៃដី ១ហ.ត

**៤-ចំណុចត្រូវចងចាំ**

- មិនត្រូវបោះបង់ចោលការប្រើប្រាស់ ***ជីធម្មជាតិ*** សំរាប់ទ្រាប់បាត
- មិនត្រូវបាចជីគីមី ***ដេ អា ប៉េ*** លើដីស្រែដែលគ្មានទឹកសោះ
- មិនត្រូវប្រើជីគីមី ***ដេ អា ប៉េ*** សំរាប់បំប៉នសន្ទូងទេ
- មិនត្រូវប្រើប្រាស់ជីគីមី ***អោយលើស*** ឬ ***ក៏ខ្វះ*** ពីសេចក្តីត្រូវការរបស់ដំណាំ ។

# ការប្រើប្រាស់ជីគីមីបំប៉នលើដំណាំស្រូវ
# (ក្រុមជីកំពង់សៀម)

**១-ប្រភេទជីគីមីដែលត្រូវប្រើ**

- ជីអ៊ុយរ៉េ (កសិករហៅថាជីឆាំងលាវ ឬជី ពងខ្យង )

**២-ពេលវេលាបាចជីបំប៉ន** បាចជីបំប៉នចំនួន ២លើកក្នុង ១វដ្តជីវិតរបស់ដំណាំស្រូវ

**-លើពូជស្រូវ អ៊ីរ៉េ ឬ កេសរ(ស្រូវស្រាល)**

+លើកទី ១ ១៥ថ្ងៃ ក្រោយស្ទូង

+លើកទី ២ ចន្លោះពី ២៨-៣១ថ្ងៃក្រោយស្ទូង

**-លើពូជស្រូវ ខា៦ (ស្រូវធ្ងន់ )**

+លើកទី ១ ៣០ថ្ងៃ ក្រោយស្ទូង

+លើកទី ២ មុនពេលស្រូវកកើតកួរ ៥ថ្ងៃ

**៣-បរិមាណជីដែលត្រូវប្រើ**

-លើកទី ១ ២៧,៥ គ.ក្រ លើផ្ទៃដី ១ហ.ត

-លើកទី ២ ២៧,៥ គ.ក្រ លើផ្ទៃដី ១ហ.ត

**៤-កំពស់ទឹក**

នៅពេលបាចជីបំប៉នត្រូវទុកទឹក កំពស់ ៣-៥ ស.ម

**៥-ចំនុចត្រូវចងចាំ**

- ជៀសវាងការបាចជីបំប៉នលើស្រែដែលគ្មានទឹកសោះ
- ជៀសវាងការបាចជីបំប៉ននៅពេលមានទឹកសន្សើម មេឃជិតភ្លៀង និង ក្រោយពេលភ្លៀងធ្លាក់ខ្លាំង
- ជៀសវាងការបាចជីបំប៉នលើស្រែដែលមានស្មៅ
- មិនអោយបាចជីបំប៉នក្រៅពីជីអ៊ុយរ៉េទេ
- មិនត្រូវបាចជីបំប៉នលើស្រែដែលមានសត្វកំពុងបំផ្លាញខ្លាំង
- ពេលបាចជីបំប៉នត្រូវរក្សាទឹកក្នុងស្រែអោយតិចបំផុត
- ត្រូវបាចជីនៅពេលត្រជាក់ ( ព្រឹក ឬល្ងាច )
- ត្រូវបាចជីអោយបានស្មើដែល
- បើមិនមានបញ្ហាអ្វីចាំបាច់ ត្រូវប្រកាន់យកថ្ងៃកំនត់ខាងលើក្នុងការប្រើប្រាស់ជីបំប៉ន ។

# ការប្រើប្រាស់ជីគីមីបំប៉នលើដំណាំស្រូវ
# (ក្រុមដីប្រទះឡាង)

**១-ប្រភេទជីគីមីដែលត្រូវប្រើ**

- ជីអ៊ុយរ៉េ (កសិករហៅថាជីឆាំងលាវ ឬជី ពងខ្យង )

**២-ពេលវេលាបាចជីបំប៉ន** បាចជីបំប៉នចំនួន ២លើកក្នុង ១វដ្តជីវិតរបស់ដំណាំស្រូវ

**-លើពូជស្រូវ អ៊ុយរ៉េ ឬ កេសរ(ស្រូវស្រាល)**

+លើកទី ១ ១៥ថ្ងៃ ក្រោយស្ទូង

+លើកទី ២ ចន្លោះពី ២៨-៣១ថ្ងៃក្រោយស្ទូង

**-លើពូជស្រូវ ខា៦ (ស្រូវធ្ងន់ )**

+លើកទី ១ ៣០ថ្ងៃ ក្រោយស្ទូង

+លើកទី ២ មុនពេលស្រូវកកើតកួរ ៥ថ្ងៃ

**៣-បរិមាណជីដែលត្រូវប្រើ**

-លើកទី ១ ៤៤ គ.ក្រ លើផ្ទៃដី ១ហ.ត

-លើកទី ២ ៤៤ គ.ក្រ លើផ្ទៃដី ១ហ.ត

**៤-កំពស់ទឹក**

នៅពេលបាចជីបំប៉នត្រូវទុកទឹក កំពស់ ៣-៥ស.ម

**៥-ចំនុចត្រូវចងចាំ**

- ជៀសវាងការបាចជីបំប៉នលើស្រែដែលគ្មានទឹកសោះ
- ជៀសវាងការបាចជីបំប៉ននៅពេលមានទឹកសន្សើម មេឃជិតភ្លៀង និង ក្រោយពេលភ្លៀងធ្លាក់ខ្លាំង
- ជៀសវាងការបាចជីបំប៉នលើស្រែដែលមានស្មៅ
- មិនអោយបាចជីបំប៉នក្រៅពីជីអ៊ុយរ៉េទេ
- មិនត្រូវបាចជីបំប៉នលើស្រែដែលមានសត្វកំពុងបំផ្លាញខ្លាំង
- ពេលបាចជីបំប៉នត្រូវរក្សាទឹកក្នុងស្រែអោយតិចបំផុត
- ត្រូវបាចជីនៅពេលត្រជាក់ ( ព្រឹក ឬល្ងាច )
- ត្រូវបាចជីអោយបានស្មើដែល
- បើមិនមានបញ្ហាអ្វីចាំបាច់ ត្រូវប្រកាន់យកថ្ងៃកំនត់ខាងលើក្នុងការប្រើប្រាស់ជីបំប៉ន ។

# ការប្រើប្រាស់ជីគីមីបំប៉នលើដំណាំស្រូវ
# (ក្រុមជីក្រុគរ និង គៀនស្វាយ)

**១-ប្រភេទជីគីមីដែលត្រូវប្រើ**

- ជីអ៊ុយរ៉េ (កសិករហៅថាជីឆាំងលាវ ឬជី ពងខ្យង )

**២-ពេលវេលាបាចជីបំប៉ន** បាចជីបំប៉នចំនួន ២លើកក្នុង ១វដ្តជីវិតរបស់ដំណាំស្រូវ

**-លើពូជស្រូវ អ៊ុយរ៉េ ឬ កេសរ(ស្រូវស្រាល) ៖**

+លើកទី ១ ១៥ថ្ងៃ ក្រោយស្ទូង

+លើកទី ២ ចន្លោះពី ២៨-៣១ថ្ងៃក្រោយស្ទូង

**-លើពូជស្រូវ ខា៦ (ស្រូវធ្ងន់ )**

+លើកទី ១ ៣០ថ្ងៃ ក្រោយស្ទូង

+លើកទី ២ មុនពេលស្រូវកកើតកួរ ៥ថ្ងៃ

**៣-បរិមាណជីដែលត្រូវប្រើ**

-លើកទី ១ ៦២ គ.ក្រ លើផ្ទៃដី ១ហ.ត

-លើកទី ២ ៦២ គ.ក្រ លើផ្ទៃដី ១ហ.ត

**៤-កំពស់ទឹក**

នៅពេលបាចជីបំប៉នត្រូវទុកទឹក កំពស់ ៣-៥ស.ម

**៥-ចំនុចត្រូវចងចាំ**

- ជៀសវាងការបាចជីបំប៉នលើស្រែដែលគ្មានទឹកសោះ
- ជៀសវាងការបាចជីបំប៉ននៅពេលមានទឹកសន្សើម មេឃជិតភ្លៀង និង ក្រោយពេលភ្លៀងធ្លាក់ខ្លាំង
- ជៀសវាងការបាចជីបំប៉នលើស្រែដែលមានស្មៅ
- មិនអោយបាចជីបំប៉នក្រៅពីជីអ៊ុយរ៉េទេ
- មិនត្រូវបាចជីបំប៉នលើស្រែដែលមានសត្វកំពុងបំផ្លាញខ្លាំង
- ពេលបាចជីបំប៉នត្រូវរក្សាទឹកក្នុងស្រែអោយតិចបំផុត
- ត្រូវបាចជីនៅពេលត្រជាក់ (ព្រឹក ឬល្ងាច )
- ត្រូវបាចជីអោយបានស្មើដែល្អ
- បើមិនមានបញ្ហាអ្វីចាំបាច់ ត្រូវប្រកាន់យកថ្ងៃកំនត់ខាងលើក្នុងការប្រើប្រាស់ជីបំប៉ន ។

# វដ្តជីវិតរបស់ដំណាំស្រូវ

**គោលបំណង** ដើម្បីប្រើប្រាស់ជីអោយមានប្រសិទ្ធិភាពលើដំណាំស្រូវ ។

**១ វដ្តជីវិតរបស់ដំណាំស្រូវ មាន ៣វគ្គ**

**៣វគ្គ**

**វគ្គលូតលាស់** | **វគ្គបង្កបង្កើតផល** | **វគ្គទុំ**

| វគ្គលូតលាស់ | វគ្គបង្កបង្កើតផល | វគ្គទុំ |
|---|---|---|
| រយៈពេលប្រែប្រួលទៅតាមអាយុប្រភេទពូជស្រូវ (ស្រាល ឬកណ្ដាល ឬធ្ងន់) | មានរយៈពេល ៣៥ថ្ងៃ | មានរយៈពេល ៣០ថ្ងៃ |

**១ វដ្តជីវិតរបស់ដំណាំស្រូវមាន ១០ដំណាក់កាល**

| ដំណាក់កាលទាំង១០ និងការបរិយាយ | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| **ដុះពន្លក** | **សំណាប** | ***បែកគុម្ព*** | ***ពន្លូតដើម*** | **កំណើតកួរ** | **ផើម** | **ចេញកួរ+ផ្កា** | **ដាក់ទឹកដោះ** | **ដាក់ម៉ៅ្យ** | **ទុំ** |
| ចាប់ពីដុះពន្លកដល់មានស្លឹកទី១ក្នុងដើម | ចាប់ពីស្លឹកទី១ ដល់មានក្លៀង | ពីបែកគុម្ពតំបូងដល់បែកគុម្ពពេញទំហឹង ***(បំប៉នជីលើកទី១)*** | ពីបែកគុម្ពពេញទំហឹងដល់ចាប់ពន្លកកកួរ ***(បំប៉នជីលើកទី២)*** | ពីកកើតកួរដំបូងដល់មានរាងជាត្រីកោណ ១-២,៥ មីលីម៉ែត្រ | ចាប់កំនើតកកួរដល់មានជាស្រកីក្នុងផើម | ពីស្រកីចេញពីស្រទបស្លឹកទៅជាផ្កា | ទឹកដោះរាវ (អាចហូរបាន) | ពីទឹកដោះរាវទៅទឹកដោះរឹង | ពីម៉ៅ្យរឹងទៅទុំ |

| **វគ្គលូតលាស់មាន ៤ដំណាក់កាល** | **វគ្គបង្កបង្កើនផលមាន ៣ដំណាក់កាល** | **វគ្គទុំមាន ៣ដំណាក់កាល** |
|---|---|---|

**ចំនុចត្រូវចងចាំ**

១-រយៈពេលនៃវគ្គលូតលាស់ប្រែប្រួលទៅតាមប្រភេទស្រូវ ស្រាល កណ្ដាល និងធ្ងន់

២-រយៈពេលវគ្គបង្កបង្កើតផលទៅដល់វគ្គទុំ មានចំនួន ៦៥ថ្ងៃ ដូចគ្នា (គ្រប់ប្រភេទស្រូវ)

៣-ត្រូវប្រើប្រាស់ជីគីមីបំប៉ន នៅក្នុងវគ្គលូតលាស់តែប៉ុណ្ណោះ

៤-ប្រើប្រាស់ជីត្រឹមត្រូវ គឺមិនខ្ជះខ្ជាយប្រាក់កាស់ ហើយមានប្រសិទ្ធិភាព ។

# ការបន្សុទ្ធគ្រាប់ពូជស្រូវដោយកសិករ

**១-របៀបអនុវត្តន៍**

**ក-ការជ្រើសរើសស្រែសំរាប់ទុកពូជ**

កំណត់យកកូនស្រែ ១ ឬ ២ដែលមានជីជាតិល្អ និងងាយស្រួលដល់ការបញ្ចេញបញ្ចូលទឹក ។

**ខ-ការពិនិត្យពូជស្រូវដែលដុះលាយ និងកំចាត់ចេញ**

-ពូជស្រូវដែលលាយវាបង្ហាញភាពខុសគ្នា នៅដំនាក់កាលបែកគុម្ពពេញទំហឹង ឬដំណាក់កាលចេញកួរចេញផ្កា

-យើងត្រូវមើលចំនុចខុសគ្នានៅ កំពស់ដើម ពេលវេលានៃការចេញកួរ ស្លឹក ដើម ពណ៌គ្រាប់ ដំណកកួរ ប្រភេទកួរស្រូវ ទំហំគ្រាប់ស្រូវ វត្តមាននៃការដុះកន្ទុយរបស់ស្រូវ ។

-បើយើងពិនិត្យឃើញមានភាពខុសគ្នាពីដើមស្រូវដែលយើងចងបានត្រូវដកចោល ។

**គ-ការច្រូតកាត់ បោកបែន សំអាត រក្សាទុក**

**-ការច្រូតកាត់**

+ស្រូវទុំចាប់ពី ៩៥ ភាគរយឡើង

+ដាក់កណ្តាប់ស្រូវដែលទុកពូជអោយឆ្ងាយពីប្រភេទស្រូវផ្សេងៗ

**-ការបោកបែន**

+ត្រូវបោកថ្នមៗ ឬជាន់នឹងជើង

**-សំអាតគ្រាប់ពូជ** ក្រោយពីបោកហើយត្រូវសំអាតគ្រាប់ពូជអោយបានស្អាតល្អ

**-ការហាលថ្ងៃ**

+ហាលលើកន្ទេល ឬលានស៊ីម៉ង់ ដែលស្អាត (ស្អាត និងមិនមានគ្រាប់ពូជផ្សេងៗ)

+ហាលរយៈពេល ៣-៥ថ្ងៃ នៅក្រោមពន្លឺថ្ងៃ

+ហាលលុះត្រាគ្រាប់មានសំណើម ១៤ភាគរយ ឬគ្រាប់ស្រូវឡើងស្រួយ ទើមយកទុក

**-ការទុកដាក់**

+ក្រោយពីបោករួចត្រូវយកគ្រាប់ពូជដាក់ក្នុងថងមួយស្អាត

+ត្រូវសរសេរឈ្មោះពូជ ថ្ងៃច្រូតកាត់ ប្រភពរបស់ពូជចំនួន ២សន្លឹក ដូចគ្នា ១ទុកក្នុងបាវ និង ១ទៀតចងភ្ជាប់នឹងបាវ ។

+ត្រូវទុកនៅកន្លែងស្ងួត និងគ្មានសត្វបំផ្លាញ ។

# ការប្រមូលផលស្រូវ

**១-ពេលវេលាច្រូតកាត់**

-នៅចន្លោះ ពី ២៨-៣៤ថ្ងៃក្រោយពីស្រូវចាប់ផ្តើមចេញផ្កា (នៅរដូវប្រាំង) និងនៅចន្លោះ ៣៤-៣៨ថ្ងៃក្រោយពីស្រូវចាប់ផ្តើមចេញផ្កា (នៅរដូវវស្សា )

-ពេលស្រូវទុំ ៨០ភាគរយ

-បើយើងច្រូតមុន និងក្រោយពេលកំណត់នោះ ធ្វើអោយគុណភាពគ្រាប់អង្ករមិនល្អ និងខ្ទេចនៅពេល កិន។

**២-ការហាល**

-ហាលដោយកំដៅថ្ងៃ រយះពេល ៣-៥ថ្ងៃ អាស្រ័យទៅតាមអាកាសធាតុ នៃតំបន់នីមួយៗ

**៣-ការសំអាត**

ប្រព្រឹត្តិទៅក្រោយ ឬមុនពេលហាលគ្រាប់ដើម្បី សំអាតស្មៅ កំទេចកំទី គ្រួស ឬថ្មតូចៗចេញពីស្រូវរបស់យើង ។

**៤-ការទុកដាក់**

-ត្រូវទុកស្រូវនៅក្នុងបាវ ឬជង្រុកអោយផុតពីដី

-ជង្រុកត្រូវអោយមានខ្យល់ចេញចូលល្អ

-ត្រូវការពារមិនអោយត្រូវទឹកភ្លៀង និងសត្វបំផ្លាញ ។

# ដង្កូវបំពង់កាត់ស្លឹក

**១-លក្ខណៈទូទៅ**

មេអំបៅចូលចិត្តពន្លឺភ្លើង វាពងនៅក្រោមផ្ទៃស្លឹក ដែលធ្លាក់សំយ៉ាកទៅលើផ្ទៃទឹក ។ ការបំផ្លាញមាននៅក្នុងស្រែដែលមានទឹកដក់ជាប់ ។ វាកើតមាននៅលើស្រែបញ្ចេញបញ្ចូលទឹក និងស្រែទទួលរបបទឹកឡើង ។ ដង្កូវរស់នៅក្នុងបំពង់ស្លឹកដែលវាកាត់បំផ្លាញបណ្តែតលើផ្ទៃទឹក ។

**២-ខួបជីវិត**

**៣-ការបំផ្លាញ**

-បំផ្លាញចាប់ពីសំណាបរហូតដល់សន្ទូង

-វាស៊ីបំផ្លាញស្លឹកដោយកោសជាលិការស្លឹក

-ការបំផ្លាញរបស់វាមាន ២ យ៉ាងគឺ

+ស្នាមកោសស្លឹកស្រូវរាងជាថ្នាក់ៗ ដូចកាំជណ្តើរ

+ស្នាមកាត់ចុងស្លឹកដាច់ដូចគេកាត់នឹងកន្ត្រៃ

**៤-វិធានការការពារ និងកំចាត់**

-ធ្វើថ្នាលសំណាបគោក

-ស្ទូងសំណាបចាស់ដើម

-បង្ហូរទឹកចេញពីស្រែរយៈពេល ២-៣ថ្ងៃ

-ដង្កូវ និងមេអំបៅ ត្រូវស៊ីបំផ្លាញដោយពពួកប៉ារ៉ាស៊ីត និងប្រេដាទ័រដូចជា ឪម៉ាល់ ពីងពាង ស្រឹង ទឹកជើងវែង ។

# មមាចត្នោត

**១-លក្ខណៈទូទៅ**

-មមាចត្នោតកើតមាននៅលើស្រែដែលប្រើប្រាស់ប្រព័ន្ធស្រោចស្រព និងស្រែទទួលរបបទឹកភ្លៀង

-មមាចត្នោតអាចកើតមានច្រើនបំផុត នៅពេលប្រើប្រាស់ថ្នាំពុលមិនសមស្រប

-មមាចត្នោតចូលចិត្តពន្លឺភ្លើងណាស់

-វាចាក់ចូលពងរបស់វាជាកញ្ចុំទៅក្នុងជាលិកាក្នុងស្រទបស្លឹក ឬទ្រនុងស្លឹក

**២-វដ្តជីវិត**

**៣-ការបំផ្លាញ**

កូន និងមេចំណាស់ បំផ្លាញដោយជញ្ជក់យករុក្ខរសពីដើមស្រូវដែលបណ្តាលអោយដើមស្រូវស្ងួត ហើយប្រែពណ៌ទៅជាត្នោត ដែលកសិករហៅថា ***ក្រាភ្លើង*** ។ ម្យ៉ាងទៀតវាជាភ្នាក់ងារចំលងវីរុសពីរុក្ខជាតិមួយទៅរុក្ខជាតិមួយទៀត ។

**៤-វិធានការការពារ និងកំចាត់**

-ភ្ជួរគល់ជញ្ជ្រាំងដែលដុះសារ

-ប្រើប្រាស់ជីអោយបានត្រឹមត្រូវទៅតាមកំរិតរបស់អ្នកបច្ចេកទេស

-បង្ហូរទឹកចេញពីស្រែ ពី ២-៣ថ្ងៃ ពេលមានវត្តមានសត្វមមាច

-ថ្នាលសំណាបធ្វើអោយឆ្ងាយពីពន្លឺភ្លើង

-ពួកប្រេដាទ័រ ( ពីងពាង ស្រមោច កន្ទុំរុយ អណ្តើកមាស ស្រឹងទឹក ) ចាប់មេ និងកូន មមាច ស៊ីជាអាហារ

-ពួកឃ្មុំ ប៉ារ៉ាស៊ីត លើពងរបស់មមាចត្នោត

-ផ្សិតបង្ករោគដល់មមាចត្នោត ។

# មមាចខៀវ

**១-លក្ខណៈទូទៅ**

-មមាចខៀវកើតមាននៅលើស្រែដែលប្រើប្រាស់ប្រព័ន្ធស្រោចស្រព និងស្រែទទួលរបបទឹកភ្លៀង

-មមាចខៀវអាចកើតមានច្រើនបំផុត នៅពេលប្រើប្រាស់ថ្នាំពុលមិនសមស្រប

-មមាចខៀវចូលចិត្តពន្លឺភ្លើងណាស់

-មមាចញោតពងតំរៀបនៅក្នុងជាលិកាក្នុងស្រទបស្លឹក ឬទ្រនុងស្លឹក

**២-វដ្តជីវិត**

**៣-ការបំផ្លាញ**

-ជញ្ជក់យករុក្ខរសពីស្លឹកស្រូវ

-ធ្វើអោយដើមស្រូវក្រិន

-មេ និងកូនចំណាស់ ជាភ្នាក់ងារចំលងជំងឺវីរុស ដែលបណ្តាលអោយស្រូវ ក្រិនលឿង ស្លឹកតុងហ្គោ

**៤-វិធានការការពារ និងកំចាត់**

-ដាំដំណាំឆ្លាស់

-ដាំដុះស្របពេលតែមួយ

-ភ្ជួរស្រែក្រោយពេលច្រូតកាត់

-ថ្នាលសំណាបធ្វើអោយឆ្ងាយពីពន្លឺភ្លើង

-ពង កូនញាស់ មេ ត្រូវស៊ីដោយពួកប៉ារ៉ាស៊ី (ឱម៉ាល់ និង ពួកប្រេដាទ័រដូចជាៈ ពីពាង កណ្តូបអង់តែនវែង កន្ទុំរុយ អណ្តើកមាស ស្រឹងគោក ខ្មូតដី )។

# ស្រីងជញ្ជក់ទឹកដោះ

**១-លក្ខណៈទូទៅ**

-ស្រីងជញ្ជក់ទឹកដោះមានពណ៌ត្នោតបៃតង

-វាមានសកម្មភាពនៅពេលព្រឹកព្រលឹម និងពេលល្ងាច ហើយវាមិនចូលចិត្តពន្លឺភ្លើងទេ

-វាពង ២-៣ជួរនៅតាមបណ្តោយទ្រនុងស្លឹកស្រូវ ។

**២-វដ្តជីវិត**

**៣-ការបំផ្លាញ**

-សត្វស្រីងវាបំផ្លាញស្រូវនៅពេលស្រូវដាក់ទឹកដោះ

-វាចុច និងបឺតយកទឹកដោះស្រូវដែលធ្វើអោយស្រូវមានស្នាមដាំខ្មៅ ដាក់គ្រាប់មិនពេញ និងបាក់គ្រាប់អង្ករ

**៤-វិធានការការពារ**

-សំអាតស្មៅក្នុងស្រែអោយបានស្អាត

-ដាំដុះស្របពេលគ្នា

-ពង កូន មេ ត្រូវបានបំផ្លាញដោយពពួកសត្វមានប្រយោជន៍ ពពួកឪម៉ាល់ ពីងពាង កណ្តូបអង់ តែនវែង ចង្រិតកណ្តុល

-ប្រើនុយស្អុយ

-ប្រើកៅស៊ូដុតបណ្តេញ

-យកមុងអូស

-បាញ់ទឹកសាប៊ូក្រអូប ឬ បុកស្រីងបាញ់ ។

# ដង្កូវស៊ីរូងដើមពណ៌លឿង

**១-លក្ខណៈទូទៅ**

-មេអំបៅរបស់វារកស៊ីនៅពេលយប់ និងចូលចិត្តពន្លឺភ្លើង

-វាពងជាសំបុកដាក់លើស្លឹកស្រូវផ្នែកខាងចុង

-ការបំផ្លាញរបស់ដង្កូវស៊ីរូងដើម ច្រើនមានភាពរាលដាល និងមានគ្រប់ទីកន្លែង ជាពិសេសនៅចុងរដូវ ភ្លៀង

-ដង្កូវរស់នៅ និងបំពេញវគ្គលូតលាស់របស់វានៅក្នុងដើមស្រូវ ។

**២-វដ្តជីវិត**

**៣-លក្ខនៃការបំផ្លាញ**

ការបំផ្លាញមានពីរដំណាក់កាលគឺ

**ក- <u>ដំណាក់កាលស្រូវបែកគុម្ព</u>** បណ្ដាលអោយដើមស្រូវ ***ងាប់បណ្ដូល***

**ខ- <u>ដំណាក់កាលពេលស្រូវចេញផ្កា</u>** បណ្ដាលអោយកួរស្រូវឡើង ***ពណ៌ស***

**៤-វិធានការការពារ និងកំចាត់**

- ប្រមូលសំបុកពងពីក្នុងស្រែ
- កាត់ចុងសំណាបមុនពេលស្ទូង
- ដាំដុះស្របពេលគ្នា
- ភ្ជួរដីហាល ឬពន្លិចទឹកចោលក្រោយពេលច្រូតកាត់
- ចៀសវាងប្រើជីអាសូតច្រើនហួស
- ដាំដំណាំឆាស់មុខគ្នា
- ពង ដង្កូវ មេអំបៅ ត្រូវបំផ្លាញដោយពួកសត្វមានប្រយោជន៍ដូចជា ពួកឪម៉ាល់ ពីងពាង ……… ។

# គំរិតណែនាំការប្រើប្រាស់ជីសំរាប់ផលិតកម្មដំណាំស្រូវ

| ល.រ | ក្រុមដី | បទដ្ឋានជី<br>Noo,Poo,Koo | ចំនួនជី(គ.ក្រ)<br>CARDI | | ចំនួនជី(គ.ក្រ)<br>Extension | | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ១ | កំពងសៀម | 50-00-00 | -Urea | : 109Kg | Urea | : 110 kg | ពូជទំនើបឬប្រពៃណី |
| | | 98-18-00 | -Dap<br>-Urea | : 39 kg<br>: 197 kg | Dap<br>Urea | : 40 kg<br>: 200 kg | ពូជទំនើបឬប្រព្រណី<br>(រដូវប្រាំង) |
| ២ | កៀនស្វាយ<br>ឬ តែគរ | 120-35-00 | -Dap<br>-Urea | : 54 kg<br>: 239 kg | Dap<br>Urea | : 50 kg<br>: 125 kg | ពូជទំនើប ឬ ពូជប្រពៃណី |
| | | 66-23-00 | | | Dap<br>Urea | : 50 kg<br>: 124 kg | ពូជទំនើប ឬពូជប្រពៃណី |
| ៣ | ប្រទះឡាំង | 50-23-30 | -Dap<br>-Kcl<br>-Urea | : 50 kg<br>: 50 kg<br>: 89 kg | Dap<br>Kcl<br>Urea | : 50 kg<br>: 50 kg<br>: 90 kg | ពូជទំនើប ឬពូជប្រពៃណី<br>(ករណីមានទឹកគ្រប់គ្រាន់ ) |
| | | 33-23-00 | -Dap<br>-Urea | : 50 kg<br>: 52 kg | Dap<br>Urea | : 50 kg<br>: 50 kg | ពូជទំនើប ឬពូជប្រពៃណី<br>(ករណីមានទឹកគ្រប់គ្រាន់ ) |
| ៤ | ទួលសំរោង | 98-23-00 | -Dap<br>Urea | : 76 kg<br>: 184 kg | Dap<br>Urea | : 75 kg<br>: 184 kg | ពូជទំនើប |
| | | 61-24-00 | Dap<br>Urea | : 52 kg<br>: 113 kg | Dap<br>Urea | : 50kg<br>: 113kg | ពូជប្រពៃណី |
| ៥ | ព្រៃខ្មែរ | 28-10-40 | Dap<br>Kcl<br>Urea | : 21 kg<br>: 67 kg<br>: 52 kg | Dap<br>Kcl<br>Urea | : 25 kg<br>: 67 kg<br>: 50 kg | ពូជទំនើប ឬពូជប្រពៃណី |
| | | 20-08-00 | Dap<br>Urea | : 17 kg<br>: 37 kg | Dap<br>Urea | : 17 kg<br>: 38 kg | ពូជទំនើប ឬពូជប្រពៃណី |
| ៦ | បាកានឬអូររាំង | 75-30-30 | Dap<br>Kcl<br>Urea | : 65 kg<br>: 50 kg<br>: 137 kg | Dap<br>Kcl<br>Urea | : 65 kg<br>: 50 kg<br>: 140 kg | ពូជទំនើប |
| | | 75-30-00 | Dap<br>Urea | : 65 kg<br>: 17 kg | Dap<br>Urea | : 65 kg<br>: 140 kg | ពូជទំនើប |
| | | 60-17-20 | Dap<br>Kcl<br>Urea | : 37 kg<br>: 34 kg<br>: 117 kg | Dap<br>Kcl<br>Urea | : 38 kg<br>: 34 kg<br>: 117 kg | ពូជប្រពៃណី |
| | | 60-17-00 | Dap<br>Urea | : 37 kg<br>: 117 kg | Dap<br>Urea | : 38 kg<br>: 117 kg | ពូជប្រពៃណី |
| ៧ | ក្បាលពោធិ៍ | 80-00-00 | Urea | : 175 kg | Urea | : 175 kg | ពូជទំនើប ឬប្រពៃណី |
| ៨ | ដីគោកគ្រប់<br>ខ្សត់ជីជាតិ | 73-35-30 | Dap<br>Ksl<br>Urea | : 76 kg<br>: 50 kg<br>: 122 kg | Dap<br>Kcl<br>Urea | : 75 kg<br>: 50 kg<br>: 125 kg | ពូជទំនើប |
| | | 65-30-00 | Dap<br>Urea | : 65 kg<br>: 115 kg | Dap<br>Urea | : 65 kg<br>: 115 kg | ពូជទំនើប |
| | | 58-30-00 | Dap<br>Kcl<br>Urea | : 67 kg<br>: 50 kg<br>: 100 kg | Dap<br>Kcl<br>Urea | : 67 kg<br>: 50 kg<br>: 100 kg | ពូជប្រពៃណី |
| | | 49-23-00 | Dap<br>Urea | : 50 kg<br>: 87 kg | Dap<br>Urea | : 50 kg<br>: 88 kg | ពូជប្រពៃណី |